BRIEFING NOTES

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

អ្នកនាំពាក្យរបស់ឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្ស: *រ៉ាវីណា សេមដាសានី* (*Ravina Shamdasani*)
ទីតាំង៖ ទីក្រុងហ្សឺណែវ
កម្មវត្ថុ៖ ប្រទេសកម្ពុជា / ក្រុមជនភៀសខ្លួនម៉ុងតាញ៉ា

---

ប្រទេសកម្ពុជា / ក្រុមជនភៀសខ្លួនម៉ុងតាញ៉ា

យើងមានសេចក្តីរីករាយ សូមប្រកាសថា ការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិប្រចាំកម្ពុជា បានមានលទ្ធភាព បន្ទាប់ពីបានចំណាយពេលច្រើនសប្តាហ៍ ចូលរួមធ្វើការជាមួយអាជ្ញាធរថ្នាក់ជាតិ និងអាជ្ញាធរថ្នាក់ខេត្ត ដើម្បីផ្តល់សុវត្ថិភាពឲ្យក្រុមជនភៀសខ្លួនម៉ុងតាញ៉ាវៀតណាមចំនួន១៣ នាក់ ដែលបានលាក់ខ្លួនក្នុងព្រៃក្នុងប្រទេសកម្ពុជា ចាប់តាំងពីខែតុលាមក ដោយមិនមានការការពារពីស្ថាប័នណាមួយ និងមានអាហារតិចតួចស្តួចស្តើងសម្រាប់ទទួលទាន ។ ពួកគេបានប្រាប់ថា ពួកគេមានបំណងស្វែងរកសិទ្ធិជ្រកកោន ប៉ុន្តែអាជ្ញាធរខេត្តបានព្រមានថា ប្រសិនជារកឃើញពួកគេ អាជ្ញាធរនឹងនិរទេសត្រឡប់ទៅវិញ។

នៅសប្តាហ៍មុន ក្រុមជនភៀសខ្លួនម៉ុងតាញ៉ា បានប្រាប់ថា ពួកគេបានត្រៀមខ្លួនជាស្រេច ដើម្បីចេញមកបង្ហាញខ្លួននៅចំពោះមុខអង្គការសហប្រជាជាតិ។ នៅព្រឹកព្រលឹមថ្ងៃសៅរ៍ ជនភៀសខ្លួនម៉ុងតាញ៉ាមួយក្រុមដែលមានគ្នាចំនួនប្រាំបីនាក់ ក្នុងនោះមានស្ត្រីម្នាក់ផង បានបង្ហាញខ្លួននៅចំពោះមុខក្រុមចម្រុះរបស់អង្គការសហប្រជាជាតិ និងក្រសួងមហាផ្ទៃ ដែលបានធ្វើដំណើរទៅកាន់ខេត្តរតនគិរីកាលពីពីរសប្តាហ៍មុន។ នៅថ្ងៃនោះដែរ ក្រុមមន្ត្រីសិទ្ធិមនុស្សរបស់យើង ដែលមានគ្នាបីនាក់ និងអ្នកបើកបររថយន្តម្នាក់ បានបើកបរលើកំណាត់ផ្លូវភក់ល្បាប់ក្នុងព្រៃស្វែងរកជនភៀសខ្លួនមួយក្រុមទៀត ដែលមានគ្នាប្រាំនាក់ ដែលចង់បង្ហាញខ្លួនចំពោះមុខអង្គការសហប្រជាជាតិ។ ក្រោយមក នគរបាលខេត្ត បានប្រាប់ក្រុមយើងនេះថា ជនភៀសខ្លួនម៉ុងតាញ៉ាមួយក្រុមនេះ បាននិងកំពុងស្ថិតក្រោមការឃុំគ្រងរបស់នគរបាល។ នៅវេលាល្ងាចថ្ងៃដែលនោះ នគរបាលបានប្រគល់ជនភៀសខ្លួនម៉ុងតាញ៉ាទាំងប្រាំនាក់នោះឲ្យក្រុមចម្រុះរបស់យើង។

នៅពេលជួបពួកគេ ក្រុមយើងបានឃើញជនភៀសខ្លួនម៉ុងតាញ៉ាទាំង១៣ នាក់នោះ មានសភាពស្គមស្គាំង មានសំលៀកបំពាក់រយីករយាក និងបានត្អូញត្អែរប្រាប់យើងជាច្រើនអំពីបញ្ហាសុខភាពរបស់គាត់ ក្រោយពីបានរស់នៅរយៈពេលជាងប្រាំពីរសប្តាហ៍ ដេកផ្ទាល់ដីក្នុងព្រៃឈើ មានអាហារតិចតួចសម្រាប់ទទួលទាន។

បច្ចុប្បន្ន ក្រុមនេះបាននិងកំពុងស្ថិតក្នុងដំណើរការចុះបញ្ជី ដោយនាយកដ្ឋានទទួលបន្ទុកកិច្ចការជនភៀសខ្លួនរបស់រដ្ឋាភិបាល ដែលនឹងពិនិត្យលើពាក្យសុំសិទ្ធិជ្រកកោនរបស់ពួកគេ។

យើងសូមវាយតំលៃខ្ពស់ចំពោះកិច្ចសហការជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ និងជាមួយដៃគូដទៃទៀតរបស់យើងនៅឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកជនភៀសខ្លួន(UNHCR)។ យើងសូមអរគុណដល់ក្រសួងមហាផ្ទៃដែលបានផ្តល់កិច្ចសហប្រតិបត្តិការនៅទូទាំងអំឡុងពេលពីរខែកន្លងមកនេះ បើទោះជាជួបប្រទះការលំបាកខ្លះក្តី ជាមួយអាជ្ញាធរខេត្ត។ យើងទទួលស្គាល់ និងសូមធ្វើការកោតសរសើរចំពោះកិច្ចសហប្រតិបត្តិការរបស់អាជ្ញាធរអនុវត្តច្បាប់នៅថ្នាក់ខេត្តនៅដំណាក់កាលចុងក្រោយ ដែលនៅទីបំផុតពួកគាត់បានអនុញ្ញាតឲ្យជនភៀសខ្លួនម៉ុងតាញ៉ាទាំងប្រាំនាក់ចុងក្រោយ ដាក់ពាក្យសុំសិទ្ធិជ្រកកោន។ យើងនឹងបន្តធ្វើការជាមួយរដ្ឋាភិបាលដើម្បីធានាថា នៅថ្ងៃខាងមុខ គ្រប់ករណីបែបនេះ ត្រូវនឹងបានអនុវត្តស្របតាមបទដ្ឋានច្បាប់អន្តរជាតិ។

**ចប់**

*សម្រាប់ព័ត៌មានបន្ថែម និងការសាកសួរព័ត៌មានផ្សេងៗ សូមទាក់ទង៖ រ៉ាវីណា សេមដាសានី* (Ravina Shamdasani) *តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩១៦៩ ឬតាមរយៈអ៊ីម៉េល* rshamdasani@ohchr.org*)*

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងតាមរយៈបណ្តាញព័ត៌មានសង្គម៖**

**ហ្វេសប៊ុក:** https://www.facebook.com/unitednationshumanrights
**ធ្វីតធឺ៖** http://twitter.com/UNrightswire
**ហ្គោហ្គឹល៖ Google+** gplus.to/unitednationshumanrights
**យូធូប៖** http://www.youtube.com/UNOHCHR
**និទានរឿង៖** http://storify.com/UNrightswire